N°29
08-8-02

# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


២៩-៧-២០០២ - ព្រះរាជក្រម នស/រកម/០៧០២/០១៤ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍ សេដ្ឋកិច្ច-សង្គមកិច្ច ៥ ឆ្នាំលើកទី ២ (២០០១-២០០៥) ២១២៤

២៩-៧-២០០២ - ព្រះរាជក្រម នស/រកម/០៧០២/០១៥ ច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/ AIDS) ២១២៦


### ២-ព្រះរាជក្រឹត្យ


០២-៨-២០០២ - ព្រះរាជក្រឹត្យ នស/រកម/០៧០២/២៤១ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតិខ្មែរពីកំណើតជូនអ្នកស្រី **ស៊ូ មន្ថា** (SOU MOUNTHA) សញ្ជាតិអាមេរិក ដើមកំណើតឡាវ កើតនៅប្រទេសឡាវ ២១៤៤

០២-៨-២០០២ - ព្រះរាជក្រឹត្យ នស/រកម/០៧០២/២៤១ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់ លោក **ហ្គាវីន អានដ្រូ ម៉ែលប៊ឺន ស្កុត** (GAVIN ANDREW MILBURN SCOTT) សញ្ជាតិដើមអង់គ្លេស កើតនៅចក្រភពអង់គ្លេស ២១៤៥


## II-ក្រុមប្រឹក្សាធម្មនុញ្ញ


០៥-៨-២០០២ - សេចក្តីសំរេចលេខ ០៤៦/០០១/២០០២ កបធ.ច ២១៤៦


## III-រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ


០១-៨-២០០២ -អនុក្រឹត្យលេខ ៧៨ អនក្រ បក ស្តីពីការផ្ទេរឥណទានថវិកា ២១៤៨

០២-៨-២០០២ -អនុក្រឹត្យលេខ ៧៩ អនក្រ បក ស្តីពីការផ្ទេរឥណទានថវិកា ២១៥០

០៦-៨-២០០២ -អនុក្រឹត្យលេខ ៨០ អនក្រ បក ស្តីពីការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការ ស៊ីវិលឱ្យ ចូលនិវត្តន៍តាមអាយុ តាមប្រពន្ធ័តិមានវិទ្យា ២១៥២

០២-៨-២០០២ -អនុក្រឹត្យលេខ ៣៧៧ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ២១៥៦

០២-៨-២០០២ -អនុក្រឹត្យលេខ ៣៧៨ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ២១៥៧

០២-៨-២០០២ -អនុក្រឹត្យលេខ ៣៧៩ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ២១៥៨

០២-៨-២០០២ -អនុក្រឹត្យលេខ ៣៨០ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ២១៥៩

០២-៨-២០០២ -អនុក្រឹត្យលេខ ៣៨១ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ២១៦០

០២-៨-២០០២ -អនុក្រឹត្យលេខ ៣៨២ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ ២១៦២

| | | |
|---|---|---|
| ០៥-៨-២០០២ | -អនុក្រឹត្យលេខ ៣៨៣ អនក្រ តត ស្តីពីការ ផ្លាស់ប្តូរភារកិច្ច និងតែងតាំងមន្ត្រីរាជការ | ២១៦៣ |
| ០៥-៨-២០០២ | -អនុក្រឹត្យលេខ ៣៨៤ អនក្រ តត ស្តីពីការ ជូនមេដាយការងារ | ២១៦៤ |
| ០៥-៨-២០០២ | -អនុក្រឹត្យលេខ ៣៨៥ អនក្រ តត ស្តីពីការ ជូនមេដាយសហមេត្រី | ២១៦៦ |
| ០៥-៨-២០០២ | -អនុក្រឹត្យលេខ ៣៨៦ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ | ២១៦៧ |
| ០៥-៨-២០០២ | -អនុក្រឹត្យលេខ ៣៨៧ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ | ២១៦៨ |
| ០៥-៨-២០០២ | -អនុក្រឹត្យលេខ ៣៨៨ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ | ២១៦៩ |
| ០៦-៨-២០០២ | -អនុក្រឹត្យលេខ ៣៨៩ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ | ២១៧០ |
| ០៦-៨-២០០២ | -អនុក្រឹត្យលេខ ៣៩០ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ | ២១៧១ |
| ០៧-៨-២០០២ | -អនុក្រឹត្យលេខ ៣៩១ អនក្រ តត ស្តីពីការ ជូនមេដាយស្ថាបនាជាតិ | ២១៧២ |
| ០៧-៨-២០០២ | -អនុក្រឹត្យលេខ ៣៩២ អនក្រ តត ស្តីពីការ ជូនមេដាយការងារ | ២១៧៣ |
| ០៧-៨-២០០២ | -អនុក្រឹត្យលេខ ៣៩៣ អនក្រ តត ស្តីពីការ ជូនមេដាយការងារ | ២១៧៧ |
| ០៧-៨-២០០២ | -អនុក្រឹត្យលេខ ៣៩៤ អនក្រ តត ស្តីពីការ ជូនមេដាយការងារ | ២១៨៥ |


### ២. សេចក្តីសំរេច


| | | |
|---|---|---|
| ០២-៨-២០០២ | - សេចក្តីសំរេចលេខ ៤០ សសរ ស្តីពីការតែងតាំងសមាសភាពលេខាធិការនៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ | ២២០៩ |


## IV- ការងារបណ្តាក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


| | | |
|---|---|---|
| ២៩-៧-២០០២ | - សេចក្តីជូនដំណឹងលេខ ០២១ សហវ.ពដ | ២២១១ |
| ០១-៨-២០០២ | - ប្រកាសលេខ ៥១៥ សហវ. ប្រក ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល និងអគ្គនាយកបណ្តោះអាសន្នរបស់ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ២២១២ |
| ០៦-៨-២០០២ | - ប្រកាសលេខ ៥១៩ សហវ. ថហ ស្តីពីការបន្ថែមឥណទានជូនសាលា ខេត្តកំពង់ចាម សំរាប់ការ គ្រប់គ្រងឆ្នាំ ២០០២ | ២២១៤ |
| ០៦-៨-២០០២ | - ប្រកាសលេខ ៥២១ សហវ.វស ស្តីពីការ បង្កើតក្រុមប្រតិបត្តិសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ | ២២១៦ |


### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ


| | | |
|---|---|---|
| ០១-៨-២០០២ | - សេចក្តីសំរេចលេខ ២៤០ សសរ.កសក ស្តីពីការតែងតាំងគណៈកម្មការប្រឹក្សាថ្នាក់ ជាតិសំរាប់រៀបចំឯកសារ និង ស្រាវជ្រាវពូជសត្វនៅកម្ពុជា | ២២១៨ |

29

# គ

## ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា


០៥-៨-២០០២ - ប្រកាសលេខ ២០៥ ស.ក.ប.យ ស្តីពីការប្តូរឈ្មោះ និងបង្កើតការិយាល័យចំណុះ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជំនួយ ២២២០

០៥-៨-២០០២ - ប្រកាសលេខ ២០៦ ស.ក.ប.យ ស្តីពីការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅរបស់ការិយាល័យ ចំណុះនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង ជំនួយ ២២២១


## ៤. ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា


០៥-៨-២០០២ - ប្រកាសលេខ ៦១១ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា **ព្រែកចំបាំ** ២២២៤

០៦-៨-២០០២ - ប្រកាសលេខ ៦១៥ អយក.ប្រក ស្តីពីការបើកសាលាបឋមសិក្សា **ឃ្លាំងម្សៅ** ២២២៥

០៦-៨-២០០២ - ប្រកាសលេខ ៦១៦ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ **គោកមៀត** មកជាសាលាបឋមសិក្សាពេញលក្ខណៈ ២២២៦

០៦-៨-២០០២ - ប្រកាសលេខ ៦១៧ អយក.ប្រក ស្តីពីការបើកសាលាបឋមសិក្សា **ក្បាលកោះ** ២២២៧

០៦-៨-២០០២ - ប្រកាសលេខ ៦១៨ អយក.ប្រក ស្តីពីការបើកសាលាបឋមសិក្សា **ក្រាំងចំបក់** ២២២៨

០៦-៨-២០០២ - ប្រកាសលេខ ៦១៩ អយក.ប្រក ស្តីពីការបើកសាលាបឋមសិក្សា **ចតុមណ្ឌល** ២២២៩

០៦-៨-២០០២ - ប្រកាសលេខ ៦២០ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ **ទួលសាលា** មកជាសាលាបឋមសិក្សាពេញលក្ខណៈ ២២៣០

០៦-៨-២០០២ - ប្រកាសលេខ ៦២១ អយក.ប្រក ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ **សំបួរមាស** មកជាសាលាបឋមសិក្សាពេញលក្ខណៈ ២២៣១


## ៥. ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន


០២-៨-២០០២ -ប្រកាសលេខ ១៩៣/០២ ពម.ប្រក ស្តីពីការអនុញ្ញាតឱ្យបោះពុម្ពផ្សាយកាសែត **ព្រំដែនខ្មែរ** ដែលមានលោក **សំ ផាន់ណារិទ្ធ** ជាចាងហ្វាងការផ្សាយ ២២៣២

០២-៨-២០០២ -ប្រកាសលេខ ១៩៧/០២ ពម.ប្រក ស្តីពីការអនុញ្ញាតឱ្យផ្ទេរសិទ្ធិចាងហ្វាងការផ្សាយកាសែត "**ជាតិកម្ពុជា**" ពីលោក **ហ៊ុន ផានិត** ទៅលោក **ងឹង គីមម៉េង** ជាចាងហ្វាងការផ្សាយ ២២៣៣

០២-៨-២០០២ -ប្រកាសលេខ ១៩៨/០២ ពម.ប្រក ស្តីពីការអនុញ្ញាតឱ្យកាសែត"**កម្ពុជាសេរី**" បោះពុម្ពចែកផ្សាយឡើងវិញដោយមានលោក **ម៉ី សន្តិភាព** ជាចាងហ្វាងការផ្សាយ ២២៣៤

០២-៨-២០០២ -ប្រកាសលេខ ១៩៩/០២ ពម.ប្រក ស្តីពីការអនុញ្ញាតឱ្យទស្សនាវដ្តី"**ថ្ងៃអាទិត្យ** " ប្តូរមកជាកាសែត"**កីឡា**" វិញ និងដំណើរការបោះពុម្ពចែកផ្សាយ ដោយមានលោក **ទ្រាដ្ឋ ស៊ីម** ជាចាងហ្វាងការផ្សាយ ២២៣៥

# ព្រះរាជក្រម

នស/រកម/០៧០២/០១៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងផែនការ

# ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច៥ឆ្នាំលើកទី២ ២០០១-២០០៥ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើទី ៧ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍
# សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី២ ២០០១-២០០៥

**មាត្រា ១.-**

អនុម័តយល់ព្រមលើផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី ២ ២០០១-២០០៥ ដូចមានឯកសារភ្ជាប់មកជាមួយ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តអនុវត្តផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ឆ្នាំ លើកទី ២ ២០០១-២០០៥ នេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដាឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

៣រស.០២.០៧.០០២៥៣ **ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម រណឫទ្ធិ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ហត្ថលេខា**

**ឆាយ ថន**

លេខ : ១៧៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ព្រះរាជក្រម

នស/រកម/០៧០២/០១៥

## យើង

## ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

  បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី៨ នីតិកាល ទី២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១០ ខែ កក្កដាឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី១ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ការបង្ការ និងការប្រយុទ្ធទប់ស្កាត់

# ការរីករាលដាល

# មេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ជំងឺអេដស៍ គឺជាជំងឺឆ្លងរីករាលដាលមួយបង្កឡើងដោយមេរោគអេដស៍ និងដែលទទួលស្គាល់ថាគ្មានព្រំដែនផ្នែកដែនដី សង្គមនយោបាយនិងសេដ្ឋកិច្ច ហើយជំងឺនេះពុំទាន់មានថ្នាំព្យាបាលឱ្យជាសះស្បើយទេ ។ ការរីករាលដាលនៃជំងឺនេះ បាននិងកំពុងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើសន្តិសុខ ស្ថិរភាពនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដែលទាមទារឱ្យរដ្ឋចាត់វិធានការឆ្លើយតបជាពហុវិស័យ ដើម្បី ÷

១- ជំរុញឱ្យមានការយល់ដឹងជាសាធារណៈដល់ប្រជាពលរដ្ឋគ្រប់រូបស្តីពីមូលហេតុ របៀបនៃការចម្លង ផលវិបាក មធ្យោបាយបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) តាមរយៈកម្មវិធីអប់រំ និងយុទ្ធនាការផ្សព្វផ្សាយទូលំទូលាយទូទាំងប្រទេស ។

២- ហាមឃាត់ការរើសអើងគ្រប់ប្រភេទចំពោះរាល់បុគ្គលណា ដែលត្រូវបានសង្ស័យ ឬត្រូវបានដឹងថា មានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

៣- ជំរុញឱ្យមានការប្រុងប្រយ័ត្នជាសកលចំពោះវិធីសាស្រ្ត និងការអនុវត្តន៍ទាំងឡាយដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

៤- ចាត់វិធានការសមស្រប ចំពោះរាល់កត្តាទាំងឡាយដែលធ្វើឱ្យកាន់តែធ្ងន់ធ្ងរដល់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

៥- លើកទឹកចិត្តឱ្យមានតួនាទីជាសក្តានុពលរបស់បុគ្គល ដែលមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ក្នុងការលាតត្រដាងពត៌មាននិងបទពិសោធន៍របស់ពួកគេដើម្បីចង្អុលបង្ហាញដល់សាធារណជន ។

៦- បញ្ចូលកម្មវិធីបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ជាកម្មវិធីអាទិភាពទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ ។

## ជំពូកទី២
## ការអប់រំ និងការផ្សព្វផ្សាយពត៌មាន

### មាត្រា ៣.-

រដ្ឋត្រូវជំរុញការអនុវត្តន៍មួយចំនួនដូចខាងក្រោម ÷

១- រៀបចំឱ្យមានការបញ្ជ្រាបបញ្ចូលចំណេះដឹងស្តីពីមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) នៅក្នុងសាលារៀន ។ ការអប់រំនេះត្រូវបញ្ចូលការបង្រៀនស្តីពីមូលហេតុរបៀបនៃការចម្លងនិងការបង្ការ ផលវិបាកនៃមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ព្រមទាំងជំងឺកាមរោគដទៃទៀតជាពិសេសផ្តោតលើបំណិនជីវិតស្របនឹងសីលធម៌សង្គម តាមរូបភាពការបញ្ជ្រាបបញ្ចូលនៅក្នុងកម្មវិធីសិក្សាតាមគ្រប់គ្រឹះស្ថានសិក្សា ភូមិសិក្សារួមទាំងការអប់រំក្រៅប្រព័ន្ធ ។

២- រៀបចំឱ្យមានសិក្ខាសាលា និងការបណ្តុះបណ្តាលបង្ហាត់បង្រៀនស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ដល់គ្រូបង្រៀន និងអ្នកបង្ហាត់បង្រៀនផ្សេងទៀត ដែលត្រូវបានចាត់តាំងឱ្យទៅបង្រៀនបន្ត ។

៣- រៀបចំឱ្យមានការផ្តល់យោបល់ពីសំណាក់សហគមន៍ សមាគម អង្គការនានាក្នុងការអប់រំស្តីពីមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

### មាត្រា ៤.-

រដ្ឋរៀបចំឱ្យមានការអប់រំស្តីពីមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) បញ្ចូលជាផ្នែកមួយនៃការផ្តល់សេវាសុខាភិបាល តាមរយៈគ្រូពេទ្យនិងមន្ត្រីសុខាភិបាល ។ ចំណេះដឹងនិងសមត្ថភាពរបស់មន្ត្រីសុខាភិបាលទាំងនេះ ត្រូវបានទទួលការបំពាក់បំប៉នបន្ថែមរួមមានជំនាញសម្រាប់ផ្សព្វផ្សាយពត៌មាន និងការអប់រំស្តីពីមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

ការអប់រំផ្សព្វផ្សាយស្ដីពីមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ព្រមទាំងការបំពាក់បំប៉នបន្ថែម ក៏ជាភារកិច្ចរបស់អ្នកផ្ដល់សេវាថែទាំសុខភាពនៅក្នុងផ្នែកឯកជន ដើម្បីរួមចំណែកក្នុងការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS)។

ការបំពាក់បំប៉នបន្ថែមត្រូវរួមបញ្ចូលការពិភាក្សាអំពីបញ្ហាក្រមសីលធម៌ ដែលទាក់ទងទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ជាពិសេសការរក្សាភាពសម្ងាត់ ការគោរពសិទ្ធិបុគ្គល ។

## មាត្រា ៥.-

រដ្ឋរៀបចំឱ្យមានការផ្សព្វផ្សាយពត៌មាន និងកម្មវិធីសិល្បៈអប់រំស្ដីពីមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) នៅតាមប្រព័ន្ធផ្សព្វផ្សាយទាំងអស់ដោយឥតបង់ថ្លៃ ដើម្បីឱ្យបានជ្រួតជ្រាបដល់សាធារណជន ។

ការផ្សព្វផ្សាយនេះ ត្រូវប្រើប្រាស់វិធីសាស្ត្រនិងពេលវេលាសមស្របដើម្បីធានានូវប្រសិទ្ធិភាព ។

## មាត្រា ៦.-

រដ្ឋរៀបចំឱ្យមានការអប់រំ ពិសេសស្ដីពីមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ផ្ដោតទៅលើក្មេងស្រី ស្ត្រីជាមេគ្រួសារ ដោយត្រូវយកចិត្តទុកដាក់សំខាន់អំពីតួនាទីរបស់ស្ត្រីនៅក្នុងសង្គម និងបញ្ហាយេនឌ័រ ។

## មាត្រា ៧.-

រដ្ឋរៀបចំឱ្យមានឯកសារអប់រំស្ដីពីមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ដល់ភ្ញៀវទេសចរណ៍និងអ្នកឈប់សំចតនៅតាមច្រកចេញ-ចូលអន្តរជាតិ ។ ឯកសារអប់រំនេះត្រូវបោះពុម្ពជាភាសាខ្មែរ និងភាសាផ្សេងទៀតតាមការចាំបាច់ ។

## មាត្រា ៨.-

រដ្ឋរៀបចំផ្ដល់ពត៌មាន ឯកសារអប់រំ ឬការចូលរួមក្នុងសិក្ខាសាលាជូនដល់គ្រប់កម្មករខ្មែរ មន្ត្រីការទូត មន្ត្រីរាជការស្ដីពីមូលហេតុ របៀបនៃការចម្លង ការបង្ការនិងផលវិបាកនៃមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) មុននឹងចេញទៅបរទេស ។

## មាត្រា ៩.-

គ្រប់ស្ថាប័ន គ្រប់សហគ្រាស សិប្បកម្ម ត្រូវសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំឱ្យមានកម្មវិធីអប់រំស្ដីពីមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) នៅកន្លែងធ្វើការ ដោយត្រូវបញ្ចូលទាំងប្រធានបទ ចំពោះការរក្សាភាពសម្ងាត់នៅកន្លែងធ្វើការ និងឥរិយាបទចំពោះអ្នកមានមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) ។

ជាមួយគ្នានឹងការអប់រំស្ដីពីមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) គ្រប់ស្ថាប័ន គ្រប់សហគ្រាស សិប្បកម្ម ត្រូវរៀបចំឱ្យមានផែនការទៅតាមអាណត្តិការងាររបស់ខ្លួន ក្នុងការរួមចំណែកទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍ ។

## មាត្រា ១០.-

រដ្ឋត្រូវចលនាពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ គ្រួសារ អង្គការនានា ព្រះសង្ឃ ក្រុមបព្វជិតសាសនា និងក្រុមអ្នកដែលប្រឈមនឹងគ្រោះថ្នាក់បំផុត ដើម្បីរៀបចំផ្ដល់ពត៌មាន និងការអប់រំស្ដីពីមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) នៅគ្រប់លំដាប់ថ្នាក់ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ១១.-

សម្ភារៈឬវត្ថុធាតុសម្រាប់បង្ការការចម្លងមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) ដែលផ្ដល់ដោយលក់ឬជាអំណោយ ត្រូវភ្ជាប់ឯកសារអប់រំដែលបោះពុម្ពជាភាសាខ្មែរ និងជាភាសាផ្សេងទៀតតាមការចាំបាច់ ហើយក្នុងនោះមាននិយាយពីវិធីប្រើប្រាស់ត្រឹមត្រូវនូវសម្ភារៈឬវត្ថុធាតុទាំងនោះនិងប្រសិទ្ធិភាពរបស់វាប្រឆាំងនឹងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍(HIV/AIDS) ។

**មាត្រា ១២.-**

ហាមដាច់ខាតរាល់ការឃោសនា ឬការផ្សព្វផ្សាយពាណិជ្ជកម្មដែលអះអាងពីការព្យាបាលព្រមទាំងវិធីបង្ការមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ដែលផ្ទុយនឹងវិធានការនានារបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងគោលការណ៍បច្ចេកទេសវេជ្ជសាស្ត្រ ។

## ជំពូកទី ៣
## វិធីសាស្ត្រ និងការអនុវត្តន៍ដែលមានសុវត្ថិភាព

**មាត្រា ១៣.-**

រាល់វិធីសាស្ត្រ និងការអនុវត្តន៍ទាំងឡាយ ត្រូវធ្វើទៅតាមគោលការណ៍ណែនាំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវពិគ្រោះពិភាក្សា និងសម្របសម្រួលជាមួយក្រសួងសុខាភិបាល អង្គភាពជំនាញដែលពាក់ព័ន្ធ ដើម្បីកំណត់និងផ្សព្វផ្សាយនូវគោលការណ៍ណែនាំ ស្ដីពីការប្រុងប្រយ័ត្នជាសកល ចំពោះការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ជាពិសេសក្នុងអំឡុងពេលវះកាត់ កែសម្ផស្ស ធ្វើញញួរ អប់សព សាក់ ឬការងារដទៃទៀតដែលមានលក្ខណៈស្រដៀងគ្នា ។

**មាត្រា ១៤.-**

រាល់ការប្រើប្រាស់ឈាម ជាលិកា ឬសរីរាង្គត្រូវធ្វើតេស្តមេរោគអេដស៍បញ្ជាក់ជាមុន។

**មាត្រា ១៥.-**

មិនអនុញ្ញាតឱ្យមន្ទីរពិសោធន៍ ឬអង្គភាពណាយកឈាម ជាលិកា ឬសរីរាង្គទុកសម្រាប់ប្រើប្រាស់ ដោយពុំបានធ្វើតេស្តមេរោគអេដស៍បញ្ជាក់ជាមុនឡើយ ។

**មាត្រា ១៦.-**

សាច់ញាតិ ឬអ្នកទទួលឈាម ជាលិកា ឬសរីរាង្គ មានសិទ្ធិសុំធ្វើតេស្តសាជាថ្មី មុននឹងធ្វើការចាក់បញ្ចូលឈាម បណ្ដុះជាលិកា ឬប្ដូរសរីរាង្គ លើកលែងតែក្នុងករណីសង្គ្រោះបន្ទាន់ ។

**មាត្រា ១៧.-**

ឈាម ផលិតផលឈាម និងសរីរាង្គដែលមានមេរោគអេដស៍ ត្រូវតែកំទេចចោលតាមគោលការណ៍អនាម័យត្រឹមត្រូវបំផុត ។ ក្នុងករណីចាំបាច់ ឈាម ផលិតផលឈាម ឬសរីរាង្គដែលមានមេរោគអេដស៍អាចទទួលយកបានសម្រាប់តែការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រប៉ុណ្ណោះ ។

**មាត្រា ១៨.-**

ហាមឃាត់ដាច់ខាតចំពោះអ្នកដែលដឹងថា ខ្លួនមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ទៅប្រព្រឹត្តក្នុងចេតនាចម្លងទៅអ្នកដទៃ ។

## ជំពូកទី ៤
## ការធ្វើតេស្ត និងការផ្ដល់កិច្ចប្រឹក្សា

**មាត្រា ១៩.-**

ការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ត្រូវធ្វើឡើងដោយស្ម័គ្រចិត្តនិងត្រូវមានការយល់ព្រមជាមុនពីសាមីជនផ្ទាល់ ។ ចំពោះសាមីជនជាអនីតិជន តម្រូវឱ្យមានការយល់ព្រមជាលាយលក្ខអក្សរពីអាណាព្យាបាលស្របច្បាប់ ។

បើការយល់ព្រមជាលាយលក្ខអក្សរពីអាណាព្យាបាលស្របច្បាប់ ពុំអាចធ្វើបាន ការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) អាចប្រព្រឹត្តទៅបានដោយគ្រាន់តែមានការព្រមព្រៀងពីអនីតិជន ប្រសិនបើការធ្វើតេស្តនេះ ផ្ដល់អត្ថប្រយោជន៍ផ្ទាល់ចំពោះអនីតិជននោះ ។

ចំពោះជនវិកលចរិត រដ្ឋត្រូវយកចិត្តទុកដាក់ ។

**មាត្រា ២០.-**

ហាមដាច់ខាតចំពោះការដាក់លក្ខខណ្ឌឱ្យធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) មុន និងក្រោយការអនុញ្ញាតឱ្យចូលបំរើការងារ ចូលសិក្សានៅក្នុងគ្រឹះស្ថានសិក្សានានា ក៏ដូចជាសម្រាប់ការអនុវត្តន៍សេរីភាពស្នាក់នៅ សិទ្ធិធ្វើដំណើរ ការផ្ដល់សេវាផ្នែកវេជ្ជសាស្ត្រ ឬសេវាផ្សេងទៀត ។

## មាត្រា ២១.-

ការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ដោយបង្ខំ ត្រូវអនុញ្ញាតតែក្នុងករណីមានសេចក្តីបង្គាប់របស់តុលាការ ។

## មាត្រា ២២.-

រាល់ការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ត្រូវធ្វើដោយអនាមិក ។

ក្រសួងសុខាភិបាល ត្រូវរៀបចំផ្តល់នូវយន្តការសំរាប់ធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ហើយត្រូវធានាភាពអនាមិក និងរក្សាភាពសម្ងាត់ផ្នែកវេជ្ជសាស្ត្រនៅក្នុងដំណើរការធ្វើតេស្ត ។

## មាត្រា ២៣.-

គ្រប់កន្លែងធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) អាចផ្តល់សេវានេះបានលុះត្រាតែមានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល ។ ក្រសួងសុខាភិបាល ត្រូវសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីកំណត់និងរក្សានូវស្តង់ដារសេវាមួយសមស្រប ។

## មាត្រា ២៤.-

គ្រប់កន្លែងធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ត្រូវផ្តល់កិច្ចប្រឹក្សា មុន និងក្រោយការធ្វើតេស្តដល់ជនដែលមកសុំធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។ អ្នកផ្តល់កិច្ចប្រឹក្សា នេះត្រូវមានសមត្ថភាពគ្រប់គ្រាន់ សមស្របតាមស្តង់ដារកំណត់ដោយក្រសួងសុខាភិបាល ។

## មាត្រា ២៥.-

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍និងក្រសួងសុខាភិបាល ត្រូវសហការរៀបចំនិងលើកកំពស់សមត្ថភាពសំរាប់ការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ដល់គ្រប់កន្លែងធ្វើតេស្ត ដែលមានច្បាប់អនុញ្ញាត ហើយធានាឱ្យមានការបណ្តុះបណ្តាលបុគ្គលិកជំនាញសម្រាប់ផ្តល់សេវាបែបនេះ នៅគ្រប់កន្លែងធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

## ជំពូកទី៥
## សេវាសុខាភិបាល និងសេវាគាំទ្រ

### មាត្រា ២៦.-

រដ្ឋត្រូវធានាឱ្យអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ទទួលបាននូវសេវាថែទាំសុខភាពបឋមដោយឥតបង់ថ្លៃ តាមបណ្តាញសុខាភិបាលទាំងអស់របស់រដ្ឋ និងត្រូវលើកទឹកចិត្តឱ្យមានការចូលរួមពីផ្នែកឯកជន ។

### មាត្រា ២៧.-

រដ្ឋត្រូវចលនាពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ គ្រួសារ អង្គការនានា ព្រះសង្ឃ ក្រុមបព្វជិតសាសនា និងក្រុមអ្នកដែលប្រឈមនឹងគ្រោះថ្នាក់បំផុត សំដៅឧបត្ថម្ភ ថែទាំនិងព្យាបាលអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) នៅគ្រប់លំដាប់ថ្នាក់ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២៨.-

រដ្ឋត្រូវយកចិត្តទុកដាក់ជំរុញឱ្យមានការបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់អ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ដើម្បីប្រកបរបរចិញ្ចឹមជីវិតនិងកម្មវិធីជួយខ្លួនឯង ។ អ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ត្រូវមានសិទ្ធិចូលរួមពេញលេញ នៅក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីជួយខ្លួនឯង ដើម្បីជាមធ្យោបាយចិញ្ចឹមជីវិត ។

### មាត្រា ២៩.-

រដ្ឋត្រូវយកចិត្តទុកដាក់បន្តជំរុញការបង្ការ និងការគ្រប់គ្រងជំងឺកាមរោគ ក្នុងគោលដៅជួយទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

# ជំពូកទី ៦
## ការតាមដានត្រួតពិនិត្យ

### មាត្រា ៣០.-

រដ្ឋត្រូវបង្កើតកម្មវិធីតាមដានត្រួតពិនិត្យមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ទូលំទូលាយមួយ ដើម្បីកំណត់ទំហំ ភាពងាយប្រឈមនឹងគ្រោះថ្នាក់របស់ប្រជាពលរដ្ឋ ការប្រព្រឹត្តិរួមភេទ និងការរាលដាលមេរោគអេដស៍ ជំងឺអេដស៍ (HIV/AIDS) ។

កម្មវិធីនេះមានគោលបំណងផ្ទៀងផ្ទាត់ វាយតម្លៃពីភាពគ្រប់គ្រាន់ ប្រសិទ្ធិភាពនិងនិរន្តរភាពនៃវិធានការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ ជំងឺអេដស៍ (HIV/AIDS) នៅក្នុងប្រទេស ។

### មាត្រា ៣១.-

គ្រប់កន្លែងធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ត្រូវកំណត់យកវិធានការក្នុងការធានាចំពោះការរក្សាភាពសម្ងាត់នៃរបាយការណ៍ កំណត់ត្រាវេជ្ជសាស្ត្រ ពត៌មានផ្ទាល់ខ្លួនរួមបញ្ចូលទាំងពត៌មានទាំងអស់ដែលអាចទទួលបានពីប្រភពពត៌មានផ្សេងៗ ក្នុងការអនុវត្តន៍កម្មវិធីតាមដានត្រួតពិនិត្យ ។ កម្មវិធីតាមដានត្រួតពិនិត្យនេះ ត្រូវប្រើប្រាស់នូវប្រព័ន្ធលេខកូដដើម្បីធានាឱ្យមានភាពអនាមិក ។

### មាត្រា ៣២.-

ការតាមរកប្រភពចម្លងមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) និងសកម្មភាពស្រាវជ្រាវសម្ងាត់ផ្សេងៗ ទាក់ទងនឹងសុខភាព អាចត្រូវបន្តតាមដានដោយក្រសួងសុខាភិបាលនិងស្ថាប័នពាក់ព័ន្ធ ប្រសិនបើសកម្មភាពទាំងអស់នោះ មិនផ្ទុយទៅនឹងគោលបំណងទូទៅនៃច្បាប់នេះ ។ ពត៌មានដែលទទួលបាន ត្រូវរក្សាភាពសម្ងាត់និងត្រូវរក្សាទុកឱ្យបានត្រឹមត្រូវ ។

# ជំពូកទី ៧

## ការរក្សាភាពសម្ងាត់

**មាត្រា ៣៣.-**

អ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ត្រូវទទួលបានការរក្សាភាពសម្ងាត់ ។

អ្នកមានអាជីពផ្នែកវេជ្ជសាស្ត្រ កម្មករ និយោជក ទីភ្នាក់ងារជ្រើសរើសបុគ្គលិកនានា ក្រុមហ៊ុនធានារ៉ាប់រង អ្នកបញ្ចូលទិន្នន័យ អ្នករក្សាសំណុំឯកសារទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) និងអ្នកដែលមានភារកិច្ចពាក់ព័ន្ធផ្សេងៗទៀត ត្រូវបានទទួលការណែនាំឱ្យយកចិត្តទុក ដាក់ពីការរក្សាភាពសំងាត់នៅក្នុងទំនាក់ទំនងការងារ ជាពិសេសអត្តសញ្ញាណ និងស្ថានភាពផ្ទាល់ខ្លួន របស់អ្នកមានមេរោគអេដស៍ ជំងឺអេដស៍ (HIV/AIDS) ។

**មាត្រា ៣៤.-**

ការរក្សាភាពសម្ងាត់ផ្នែកវេជ្ជសាស្ត្រត្រូវបានលើកលែងក្នុងករណី ÷

ក- តម្រូវឱ្យធ្វើរបាយការណ៍ដែលស្របទៅនឹងកម្មវិធីតាមដានត្រួតពិនិត្យមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ដូចដែលបានចែងនៅក្នុងមាត្រា ៣០ នៃច្បាប់នេះ;

ខ- ផ្តល់ព័ត៌មានទៅដល់បុគ្គលិកសុខាភិបាលដែលធ្វើការព្យាបាល ឬថែទាំអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ដោយផ្ទាល់ ឬដោយប្រយោល និង

គ- ឆ្លើយតបទៅនឹងដីកាចេញដោយតុលាការ ចំពោះបញ្ហាសំខាន់ដែលទាក់ទងទៅនឹងការមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) របស់បុគ្គលណាម្នាក់ ។ ភាពសម្ងាត់នៃកំណត់ត្រាវេជ្ជសាស្ត្រ ត្រូវដាក់ក្នុងស្រោមបិទឱ្យបានត្រឹមត្រូវដោយអ្នកគ្រប់គ្រងឯកសារ បន្ទាប់ពីត្រូវបានត្រួត ពិនិត្យយ៉ាងហ្មត់ចត់ដោយអ្នកមានភារៈទទួលខុសត្រូវព្រមទាំងប្រគល់ដោយផ្ទាល់ដៃ និងបើកជាផ្លូវការដោយចៅក្រមនៅចំពោះមុខអង្គជំនុំជំរះក្តីសម្ងាត់ ។

**មាត្រា ៣៥.-**

លទ្ធផលនៃការធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) អាចផ្តល់ឱ្យ ÷

ក- ជនដែលសុំធ្វើតេស្តមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ដោយស្ម័គ្រចិត្ត

ខ- អាណាព្យាបាលស្របច្បាប់របស់អនីតិជន ដែលត្រូវបានធ្វើតេស្តមេរោគអេដស៍/ ជំងឺអេដស៍ (HIV/AIDS).

គ- ជនដែលត្រូវបានអនុញ្ញាតឱ្យទទួលលទ្ធផលនេះ សម្រាប់កម្មវិធីតាមដានត្រួតពិនិត្យមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ដូចដែលមានចែងក្នុងមាត្រា ៣០ នៃច្បាប់នេះ និង

ឃ- តាមតម្រូវការរបស់តុលាការដូចមានចែងក្នុងចំណុច "គ" មាត្រា ៣៤ នៃច្បាប់នេះ ។

## ជំពូកទី ៨
## គោលនយោបាយ និងសកម្មភាពនៃការរើសអើង

**មាត្រា ៣៦.-**

ហាមដាច់ខាតការរើសអើងដល់ជនណាម្នាក់ តាមបែបណាមួយគិតពីមុន និងក្រោយពេលឱ្យចូលបំរើការងាររួមទាំងការជួល ការតម្លើងឋានន្តរសក្តិ ការចាត់ឱ្យបំពេញការងារ ការរួមរស់នៅក្នុងសង្គម ដោយផ្អែកលើការដឹង ឬសង្ស័យថា ជននោះ ឬក្រុមគ្រួសាររបស់ជននោះមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។ ត្រូវចាត់ទុកថា ខុសច្បាប់រាល់ការបញ្ឈប់ពីការងារចំពោះជនណាម្នាក់ដោយផ្អែកលើការដឹង ឬសង្ស័យថាជននោះ ឬក្រុមគ្រួសាររបស់ជននោះមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

**មាត្រា ៣៧.-**

គ្រប់ស្ថាប័នអប់រំបណ្តុះបណ្តាលទាំងអស់ មិនត្រូវបដិសេធ បណ្តេញ ដាក់វិន័យ ដាក់ឱ្យនៅដាច់ដោយឡែក ឬមិនអនុញ្ញាតឱ្យចូលរួមទទួលផលប្រយោជន៍ ឬសេវាផ្សេងៗចំពោះ

សិស្ស និស្សិតណាម្នាក់ ដោយសារតែការដឹង ឬសង្ស័យថា សិស្ស និស្សិតនោះ ឬក្រុមគ្រួសាររបស់សិស្ស និស្សិតនោះ មានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

**មាត្រា ៣៨.-**

អ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) មានសិទ្ធិពេញលេញក្នុងការស្នាក់នៅ និងធ្វើដំណើរ ។

គ្មានជនណាម្នាក់ត្រូវបានឃុំឃាំងឱ្យនៅដោយឡែក ដាក់ឱ្យនៅឯកោ មិនអនុញ្ញាតឱ្យចូលស្នាក់នៅ រួមដំណើរ ឬបណ្តេញចេញដោយសារតែការដឹង ឬសង្ស័យថាជននោះ ឬក្រុមគ្រួសាររបស់ជននោះ មានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

**មាត្រា ៣៩.-**

ហាមដាច់ខាតការរើសអើងចំពោះអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ក្នុងការទទួលតំណែងសាធារណៈ ។

សិទ្ធិក្នុងការស្វែងរកតំណែងសាធារណៈដោយការបោះឆ្នោត ឬការចាត់តាំងតម្លើងឋានៈ មិនត្រូវបដិសេធចំពោះជនណាម្នាក់ ដោយសារតែការដឹង ឬសង្ស័យថាជននោះ ឬក្រុមគ្រួសាររបស់ជននោះ មានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

**មាត្រា ៤០.-**

ហាមដាច់ខាតការរើសអើងចំពោះអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ក្នុងការទទួលឥណទាន និងការខ្ចីបុលទាំងអស់ រួមទាំងការធានារ៉ាប់រងសុខភាពគ្រោះថ្នាក់ និងអាយុជីវិត ក្នុងករណីដែលសាមីជន បំពេញបាននូវលក្ខខណ្ឌបច្ចេកទេសដូចពលរដ្ឋធម្មតាដែរ ។

**មាត្រា ៤១.-**

ហាមដាច់ខាតការរើសអើងចំពោះអ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) នៅក្នុងមន្ទីរពេទ្យ និងអង្គភាពសុខាភិបាលនានា ។

គ្មានជនណាម្នាក់ត្រូវបានបដិសេធមិនឱ្យទទួលសេវាថែទាំសុខភាពទាំងរដ្ឋនិងឯកជន ឬត្រូវបានទារតម្លៃខ្ពស់ ដោយសារតែការដឹង ឬសង្ស័យថា ជននោះឬក្រុមគ្រួសាររបស់ជននោះ មានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) ។

## មាត្រា ៤២.-

អ្នកមានមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) មានសិទ្ធិដូចប្រជាពលរដ្ឋធម្មតា ដូចដែលមានចែងក្នុងជំពូកទី៣ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៩
## អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ (អ.ជ.ប.ជ.អ.)

## មាត្រា ៤៣.-

ត្រូវបានបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីដឹកនាំនិងអនុវត្តការងារបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## មាត្រា ៤៤.-

នាយករដ្ឋមន្ត្រី ត្រូវតែងតាំងជាប្រធានរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។ ក្នុងករណីដែលនាយករដ្ឋមន្ត្រី មិនអាចបំពេញមុខនាទីនេះដោយផ្ទាល់បាន នាយករដ្ឋមន្ត្រី អាចចាត់តាំងសមាជិករាជរដ្ឋាភិបាលម្នាក់ជំនួស ។

## មាត្រា ៤៥.-

ការរៀបចំនិងការប្រព្រឹត្តិទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៤៦.-**

រដ្ឋត្រូវបញ្ចូលកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ ជាការងារអាទិភាពនៃកម្មវិធីអភិវឌ្ឍន៍ជាតិ នឹងត្រូវជំរុញ និងសម្រួលក្នុងការផ្តល់ថវិកាប្រចាំឆ្នាំឱ្យបានទាន់ពេលវេលា ដើម្បីឱ្យកម្មវិធីនេះទទួលបាននូវប្រសិទ្ធិភាព ។

ថវិការបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបានរៀបចំសំរាប់ក្រសួងពាក់ព័ន្ធ ខេត្ត-ក្រុង ទូទាំងព្រះរាជាណាចក្រកម្ពុជា និងត្រូវបានចាត់ជាថវិកាឧបសម្ព័ន្ធរបស់ក្រសួងសុខាភិបាល និងត្រូវបញ្ចូលទៅក្នុងជំពូកថវិកាអាទិភាព ។

**មាត្រា ៤៧.-**

ដើម្បីធានាប្រសិទ្ធិភាពនៃការឆ្លើយតបជាពហុវិស័យ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវទទួលបន្ទុកក្នុងការកៀងគរប្រភពធនធានទាំងក្នុងនិងក្រៅប្រទេស សម្របសម្រួល និងតំរង់ការប្រើប្រាស់ប្រភពធនធានទាំងនេះ ដល់ស្ថាប័នពាក់ព័ន្ធ ស្របទៅតាមស្ថានភាព និងតម្រូវការជាក់ស្តែងនៃកម្មវិធីផែនការយុទ្ធសាស្ត្រជាតិ ។

## ជំពូកទី ១០
## ទោសប្បញ្ញត្តិ

**មាត្រា ៤៨.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០(ប្រាំសែន) រៀល ដល់ ១.០០០.០០០(មួយលាន) រៀល និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ដល់ ១(មួយ)ឆ្នាំ និងត្រូវដកហូតអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈដែលពាក់ព័ន្ធ ។ ក្នុងករណីពុំរាងចាល ត្រូវផ្តន្ទាទោសទ្វេមួយជាពីរ ។ ឯមន្ត្រីរាជការត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល ។

**មាត្រា ៤៩.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១៣ មាត្រា ១៤ ឬ មាត្រា ១៥ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០០.០០០(ប្រាំសែន) រៀល ដល់១.០០០.០០០(មួយលាន) រៀល និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ខែ ដល់ ១(មួយ)ឆ្នាំ ។ ករណីពុំរាងចាលត្រូវផ្តន្ទាទោសទ្វេមួយជាពីរ ។ ទោសនេះ ពុំទាន់រាប់បញ្ចូលនូវការទទួលខុសត្រូវលើសំណងផ្នែករដ្ឋប្បវេណី និងការដកហូតអាជ្ញាប័ណ្ណប្រកបវិជ្ជាជីវៈដែលពាក់ព័ន្ធ ។ ឯមន្ត្រីរាជការត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល ។

**មាត្រា ៥០.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់)ឆ្នាំ ដល់ ១៥(ដប់ប្រាំ)ឆ្នាំ ។

**មាត្រា ៥១.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ២៣ មាត្រា ៣២ ឬមាត្រា ៣៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០.០០០(ប្រាំម៉ឺន)រៀល ដល់ ២០០.០០០(ម្ភៃម៉ឺន)រៀល និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ដល់ ៦(ប្រាំមួយ)ខែ ។ ករណីពុំរាងចាល ត្រូវផ្តន្ទាទោសទ្វេមួយជាពីរ ។ ឯមន្ត្រីរាជការត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល ។

**មាត្រា ៥២.-**

ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៦ មាត្រា ៣៧ មាត្រា ៣៨ មាត្រា ៣៩ មាត្រា ៤០ ឬមាត្រា ៤១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០(មួយសែន) រៀល ដល់ ១.០០០.០០០(មួយលាន)រៀល និងត្រូវផ្តន្ទាទោសដាក់ពន្ធ នាគារពី ១(មួយ)ខែ ដល់ ៦ (ប្រាំមួយ)ខែ ។ ករណីពុំរាងចាល ត្រូវផ្តន្ទាទោសទ្វេមួយជាពីរ ។ ឯមន្ត្រីរាជការត្រូវទទួលទណ្ឌកម្មបន្ថែមផ្នែករដ្ឋបាល ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៥៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២

ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាប់

**ប្រមុខរដ្ឋស្តីទី**

នស.រកម.០២.០៧.០០២៥៣

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ១៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវ ស៊ី តាន់**

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០២ /២៤១

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០២

## ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតិខ្មែរពីកំណើត ជូនអ្នកស្រី ស៊ូ មន្ថា (SOU MOUNTHA) សញ្ជាតិអាមេរិក ដើមកំណើតឡាវ កើតថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៤៧ នៅប្រទេសឡាវ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០២*

*ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់*

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

ពរស-០៤.០៨.០០២៥៥

លេខ: ១៧១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០២ / ២៤៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ្គាវិន អានដ្រូ ម៉ែលប៊ឺន ស្កុត** (GAVIN ANDREW MILBURN SCOTT ) សញ្ជាតិដើមអង់គ្លេស កើតថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៥៦ នៅខណ្ឌ ឆេសឺរ ក្រុងវ៉ែលស៊ី ចក្រភពអង់គ្លេស ដោយអនុញ្ញាតអោយប្តូរយកឈ្មោះថ្មី ស្កុត វីរជាតិ (SCOTT VIRAHJEAT) ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែ សីហា ឆ្នាំ ២០០២*

*ក្នុងព្រះបរមនាមនិងតាមព្រះរាជត្រាស់បង្គាប់*

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា**

**ជា ស៊ីម**

លេខ: ១៧២ច.ល

ពរល-០៧.០៨.០០៧៤៦ ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ក្រុមប្រឹក្សាធម្មនុញ្ញ** **ជាតិ សាសនា ព្រះមហាក្សត្រ**

**សំណុំរឿង**

លេខ : ០៤៩/០០៣/២០០២

ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២

**សេចក្ដីសំរេច** **ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៤៦/០០១/២០០២ កបធ.ច

ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០២

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/១៩៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្ដីពី គណបក្សនយោបាយ

-បានឃើញពាក្យបណ្ដឹងលេខ ៩៩៧ រស ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ របស់សម្ដេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា កែប្រែដោយពាក្យបណ្ដឹង លេខ ៦១៦ រស ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០២ របស់សម្ដេច **ហេង សំរិន** ប្រធានរដ្ឋសភាស្ដីទី (ដោយខុសឆ្នាំពី ២០០១ មក ២០០២ វិញ) សុំអោយក្រុមប្រឹក្សាធម្មនុញ្ញ បកស្រាយមាត្រា ៣៨ ជំពូកទី ៩ នៃច្បាប់ស្ដីពី គណបក្សនយោបាយ អំពីស្ថាប័នដែលមានសមត្ថកិច្ចផ្ដន្ទាទោស តាមសំណូមពររបស់លោក **គល់ បញ្ញា** នាយកប្រតិបត្តិគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល COMFREL) តាមពាក្យបណ្ដឹងលេខ ៣២៧/០២ គ.ប.ស.យ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០២ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០២ និងពាក្យបណ្ដឹងកែប្រែបានទទួលនៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ។

**ក្រោយពីបានស្ដាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា តាមមាត្រា ១៣៦ ថ្មី និង មាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៨ នៃ ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ពាក្យបណ្ដឹងរបស់សម្ដេចក្រុមព្រះ ព្រះប្រធានរដ្ឋសភា កែប្រែដោយពាក្យបណ្ដឹងរបស់សម្ដេច **ហេង សំរិន** ប្រធានរដ្ឋសភាស្ដីទី ខាងលើ អាចទទួលយកមកពិចារណាបាន ។

-យល់ឃើញថា តាមមាត្រា ១២៨ ថ្មី វាក្យខ័ណ្ឌទី ៣ និងទី ៤ នៃរដ្ឋធម្មនុញ្ញ : " *អំណាចតុលាការគ្របដណ្ដប់ទៅលើរឿងក្ដីទាំងអស់ រួមទាំងរឿងក្ដីរដ្ឋបាលផង ។*

*អំណាចនេះត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់* " ។

-យល់ឃើញថា :

- មាត្រា ១២៩ ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ចែងថា : " *មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី* " ។
- មាត្រា ១៣០ ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា : " *គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ* " ។
- មាត្រា ១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញ ចែងថា : " *មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា* " ។

-យល់ឃើញថា ការពិន័យដែលអាចធ្វើទៅបាន ក្រៅពីតុលាការ មានតែការពិន័យដែលមានលក្ខណៈជា *ពិន័យអន្តរការណ៍*

-យល់ឃើញថា *ការពិន័យអន្តរការណ៍* អាចធ្វើទៅបាន លុះត្រាតែមាន *ចែងច្បាស់ក្នុងច្បាប់* ព្រមទាំងចែងច្បាស់ពី *អាជ្ញាធររដ្ឋបាលដែលត្រូវអនុវត្ត* ឬច្បាប់បានអនុញ្ញាតអោយចែងក្នុងលិខិតបទដ្ឋានផ្សេងទៀតដូចជា *អនុក្រឹត្យ ប្រកាស* ។ល។ ក្រៅពីករណីនេះ អាជ្ញាធររដ្ឋបាលសាធារណៈពាក់ព័ន្ធមានភារកិច្ចត្រឹមកសាងសំណុំរឿងបញ្ជូនទៅតុលាការតែប៉ុណ្ណោះ ។

-យល់ឃើញថា បទបញ្ញត្តិក្នុងមាត្រា ៣៨ នេះមិនមានចែងអំពីសមត្ថកិច្ចណាមួយច្បាស់ ឬក៏អនុញ្ញាតឱ្យចែងក្នុងលិខិតបទដ្ឋានផ្សេងទៀតដែរ ។ ដូច្នេះក្រសួងពាក់ព័ន្ធមិនមានសមត្ថកិច្ចលើបទល្មើសនេះទេ ។

-យល់ឃើញថា ការផ្តន្ទាទោសផ្អាកសកម្មភាពគណបក្សនយោបាយជាបណ្តោះអាសន្នដែលមានចែងក្នុងមាត្រា ៣៨ ក៏ជាសមត្ថកិច្ចរបស់តុលាការដែរ ។

## **សំរេច**

មាត្រា ១ : យោងតាមមូលបទខាងលើ មានតែតុលាការទេដែលមានសមត្ថកិច្ចផ្តន្ទាទោសករណីទាក់ទងនឹងមាត្រា ៣៨ នៃច្បាប់ស្តីពី គណបក្សនយោបាយ ។

មាត្រា ២ : សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី០៥ ខែ សីហា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអនុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០២

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ប៊ិន ឈិន

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ១.០០០ លានរៀល ( មួយពាន់លានរៀល ) ពីជំពូក ៤១ (ចំណាយមិនបានគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក បកជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ) របស់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីឧបត្ថម្ភកាកបាទក្រហមកម្ពុជា សំរាប់ជួយប្រជាជន ដែលរងគ្រោះដោយគ្រោះធម្មជាតិ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៦៧...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ១៨០ លានរៀល ( មួយរយប៉ែតសិបលានរៀល ) ពីជំពូក ៥០ (ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយ ដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ក្រសួងផែនការ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើ ឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទិញសំភារៈ បំពាក់អោយលេខាធិការដ្ឋាន ក្រុមប្រឹក្សា អភិវឌ្ឍន៍សង្គមកិច្ច ដែលទើបនឹងបង្កើត ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ ៧ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៩/អនក្រ/បក ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៣៩/អនក្រ/បក ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០០ ស្តីពីគោលការណ៍រួមនៃនីតិវិធី គ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- បានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០២

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

អនុក្រឹត្យនេះមានគោលបំណង គ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមអាយុ ដោយធ្វើការផ្លាស់ប្តូរស្ថានភាពពីមន្ត្រីរាជការ ទៅជានិវត្តជន ជាពិសេសការផ្លាស់ប្តូរពីការទទួលបៀវត្ស និងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ទៅជាការទទួលប្រាក់សោធននិវត្តន៍ជំនួសវិញ ឱ្យបានទាន់ពេលវេលា ដោយប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា។

**មាត្រា ២.–**

អនុក្រឹត្យនេះ មិនអនុវត្តចំពោះការដាក់ឱ្យចូលនិវត្តន៍តាមការស្នើសុំ ការចូលនិវត្តន៍ដោយបញ្ញត្តិ និងការចូលនិវត្តន៍ដោយសារការបាត់បង់សម្បទាវិជ្ជាជីវៈទេ។

## ជំពូកទី ២

## ដំណើរការនៃការដាក់ឱ្យចូលនិវត្តន៍តាមអាយុ

**មាត្រា ៣.–**

មន្ត្រីរាជការស៊ីវិលទាំងពីរភេទ ត្រូវដាក់ឱ្យចូលនិវត្តន៍ជាកំហិតតាមអាយុ ដោយព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌនីមួយៗ របស់មន្ត្រីរាជការស៊ីវិលទាំងនោះ។

**មាត្រា ៤.–**

ជារៀងរាល់ឆ្នាំ គម្រោងផែនការស្ថិតិ និងថវិកា សម្រាប់មន្ត្រីរាជការស៊ីវិល ដែលចូលនិវត្តន៍តាមអាយុ ត្រូវរៀបចំដោយប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីជូនក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបម្រុងថវិកាសម្រាប់ឆ្នាំបន្ទាប់។ ចំពោះគម្រោងស្ថិតិ និងថវិកាសម្រាប់មន្ត្រីរាជការស៊ីវិលចូលនិវត្តន៍ដោយការស្នើសុំ ដោយបញ្ញត្តិ និងដោយសារការបាត់បង់សម្បទាវិជ្ជាជីវៈ ជាភារកិច្ចរបស់សាមីក្រសួង ស្ថាប័ននីមួយៗ។

**មាត្រា ៥.–**

បញ្ជីរាយនាមមន្ត្រីរាជការស៊ីវិលដែលត្រូវចូលនិវត្តន៍នៅគ្រប់ក្រសួង ស្ថាប័នទាំងអស់ ត្រូវបានបោះពុម្ពដោយប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានយ៉ាងតិច១២ ខែ មុនអាយុចូលនិវត្តន៍។ បញ្ជីនេះត្រូវចម្លងជូនសាមីក្រសួង ក្រសួង

សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ ។

**មាត្រា ៦.-**

ក្រសួង ស្ថាប័នសាមីទាំងអស់ ត្រូវត្រៀមរៀបចំដាក់មន្ត្រីរាជការស៊ីវិលក្នុងបញ្ជីឱ្យចូលនិវត្តន៍ស្របតាមនីតិវិធីជាធរមាន ទៅតាមប្រភេទក្របខ័ណ្ឌរបស់សាមីខ្លួននីមួយៗឱ្យបានមុន៦ ខែ នៃអាយុដែលត្រូវចូលនិវត្តន៍ ។ ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាសស្តីពីការដាក់ឱ្យចូលនិវត្តន៍ត្រូវចម្លងជូនក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ ។

**មាត្រា ៧.-**

ក្នុងករណីយឺតយ៉ាវ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវធ្វើការរំលឹកមួយដងដល់ក្រសួង ស្ថាប័នសាមី ហើយបើនៅតែមានការយឺតយ៉ាវទៀតនោះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវកាត់ឈ្មោះចេញពីតារាងទូទាត់ប្រាក់បៀវត្សជាស្វ័យប្រវត្តិ ហើយសាមីក្រសួង ស្ថាប័នត្រូវទទួលខុសត្រូវទាំងស្រុងអំពីបែបបទនៃការដាក់មន្ត្រីរាជការស៊ីវិលរបស់ខ្លួនឱ្យចូលនិវត្តន៍ ។

## ជំពូកទី ៣

## អន្តរប្បញ្ញត្តិ

**មាត្រា ៨.-**

ចំពោះមន្ត្រីរាជការស៊ីវិលដែលមានអាយុត្រូវចូលនិវត្តន៍ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមានរហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០២ ការដាក់ឱ្យចូលនិវត្តន៍ត្រូវធ្វើដោយដៃ។

**មាត្រា ៩.-**

ចំពោះបញ្ជីរាយនាមមន្ត្រីរាជការស៊ីវិលទាំងអស់ដែលមានអាយុចូលនិវត្តន៍នៅឆ្នាំ ២០០៣ ត្រូវបោះពុម្ពដោយប្រព័ន្ធព័ត៌មានវិទ្យាឱ្យបានមុនដំណាច់ខែ សីហា ឆ្នាំ ២០០២។

**មាត្រា ១០.-**

ចំពោះមន្ត្រីរាជការស៊ីវិលដែលមានអាយុត្រូវចូលនិវត្តន៍ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០៣ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៣ ការរៀបចំដាក់ឱ្យចូលនិវត្តន៍ត្រូវធ្វើឱ្យបានមុនថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០២។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១២
-គ្រប់ក្រសួង ស្ថាប័ន
-ឯ ក សា រ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៣៧៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

& & & & &

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ០២ រូប និងក្រុមហ៊ុន ០១ ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមកសាងអគារសិក្សា ០២ ខ្នង មាន ០៥ បន្ទប់ និង បង្គន់អនាម័យ ០៣ បន្ទប់ នៅសាលាឧបសម្ព័ន្ធ ផ្លូវដីក្រោម និង សាលាជំនីក ឃុំសឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក- មេដាយមាសស្ថាបនាជាតិ :**

១- លោក **ហ្គូតូ ហ៊្វុយមីញ៉ូ** (GOTO FUMIO) ថវិកា ចំនួន ១០.៥១៥,៧៧ USD

២- លោក **មាស ម៉ុនរ៉ា** ថវិកា ចំនួន ១០.៥១៥,៧៧ USD

**ខ- មេដាយប្រាក់ស្ថាបនាជាតិ :**

- ក្រុមហ៊ុន THE JAPAN TIMES ថវិកា ចំនួន ៦.៣៤៥,៧៥ USD

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣៧៨ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៤ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមកសាងព្រះវិហារ ០១ ខ្នង នៅវត្តឧត្តមបរមនិវាសម្កាក់ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក ~ មេដាយមាសស្ថាបនាជាតិ :**

១- ឧបាសក **គួន ឌី** ថវិកា ១៥.១៣០ USD
២- លោក **តិន យ៉ុន** ថវិកា ១៥.១៣០ USD
៣- ឧបាសិកា **ម៉ា ឌ៉ាន** ថវិកា ១៤.២៣០ USD

**ខ ~ មេដាយសំរិទ្ធការងារ :**

- លោកស្រី **គុជ សារឿន** ថវិកា ២.៩៨០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ០៧៥៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

& & & & &

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០២ គ្រឿង ជូនសប្បុរសជន ជនជាតិជប៉ុន ០២ រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចូលរួមក្នុងការកសាង អគារសិក្សា ០២ ខ្នង មាន ០៨ បន្ទប់ តុសិស្ស ចំនួន ១២៥ កៅអីសិស្ស ១២៥ និង តុគ្រូ ០៥ នៅក្នុងសាលាបឋមសិក្សា និង មត្តេយ្យសិក្សាភូមិវត្តតាមិម ឃុំអូរដំបង ស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :-

១- លោកស្រី **គូម៉ាដា ហិសាអិ** ( **KUMADA HISAE** ) ថវិកាចំនួន ៣១.០០០ USD

២- លោក **សៃតូ អ៊ីគូអុ** ( **SAITO IKUO** ) ថវិកាចំនួន ២០.២១២, ២៩ USD

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៣៥០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

& & & & &

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ជូនលោក **សខ ថន** ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយធ្វើជំរកស្នាក់នៅ ទិញអង្ករ ចែកជូនប្រជាជនក្រីក្រ និង ចូលរួមកសាងសមិទ្ធផលលើវិស័យសិក្សាធិការ សុខាភិបាល គមនាគមន៍ និង កសិកម្ម នៅក្នុងឃុំគាស់ក្រឡ ឃុំឆ្នាល់មាន់ ឃុំព្រះផុស ឃុំហប់ និង ឃុំដូនបា ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ចំណាយអស់ទឹកប្រាក់សរុបចំនួន ៣៩.៥៦០ ដុល្លារអាមេរិក ១៦០.០០០ រៀល និង ៤៣០.៣៥០ បាត ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូនៈ

- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ធនាគារជាតិ នៃកម្ពុជា
- ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា

  «ដើម្បីជូនជ្រាប»
- ដូចក្នុងប្រការ ៣

  «ដើម្បីអនុវត្ត»
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥១៩ សហវ.ជហ

រាជធានីភ្នំពេញ,ថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០០២

# ប្រកាស

## ស្តីពីការបន្ថែមឥណទានជូនសាលាខេត្តកំពង់ចាម សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩, ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២, ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/ ០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ១១/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- បានឃើញព្រះរាជក្រម នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់ខេត្ត ក្រុង
- បានឃើញប្រកាសលេខ ០៧៣ សហវ.ថហ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូល និងការបែងចែកឥណទានថវិកាខេត្ត ក្រុង ជូនខេត្តកំពង់ចាម សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២

- យោងប្រកាសណែនាំលេខ ១៧៧ សហវ.ថហ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការអនុវត្តថវិកាខេត្ត ក្រុង ឆ្នាំ ២០០២
- តាមសំណើលេខ ២៨៦ លខកច. ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០២ របស់សាលាខេត្តកំពង់ចាម និងចំណាររបស់សម្ដេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០២ ។

## សំរេច

**ប្រការ១:** ត្រូវបានបន្ថែមឥណទានជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) ចំនួន ៥០៧.០០០.០០០ រៀល (ប្រាំរយប្រាំពីរលានរៀលគត់) ជូនសាលាខេត្តកំពង់ចាម សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។

**ប្រការ២:** ឥណទានដូចក្នុងប្រការ ១ ខាងលើនេះ ត្រូវបានបំពេញបន្ថែមក្នុងសៀវភៅថវិកាឆ្នាំ ២០០២ របស់សាលាខេត្តកំពង់ចាម សំរាប់ចំណាយជាគុណប្រយោជន៍របស់ខេត្ត ដូចមានក្នុងតារាងខាងក្រោមនេះ ៖

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ចំណាត់ថ្នាក់ចំណាយ | ឥណទានបំពេញបន្ថែម |
|---|---|---|---|---|---|
| ១១ | ០១ | ១៤ | ០១ | បំភ្លឺសាធារណៈ និងផ្គត់ផ្គង់ទឹក | ២៤.៤៧៨.០០០រៀល |
| ១១ | ០១ | ១៤ | ០៥ | ការរៀបចំថែទាំទីផ្សារ និងទីសត្តឃាត | ១៦៨.៥៩២.០០០រៀល |
| ១១ | ០១ | ១៤ | ០៦ | ការថែទាំផ្លូវថ្នល់ សួនច្បារ និងការរៀបជាជួរ | ១៧៦.៧៣០.០០០រៀល |
| ១១ | ០១ | ១៤ | ០៨ | ការរៀបចំថែទាំនូវអាគារ សំណង់ ដែលរដ្ឋប្រគល់ឱ្យ | ១៣៧.២០០.០០០រៀល |
| **សរុបជំពូក ១១** | | | | | ៥០៧.០០០.០០០រៀល |

**ប្រការ៣:** ឯកឧត្តមអភិបាលខេត្តកំពង់ចាម ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

**ចំលងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  (ដើម្បីជូនជ្រាប)
- រតនាគារជាតិ
- រតនាគារខេត្តកំពង់ចាម
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ចាម
  "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៥៧១ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមប្រតិបត្តិសំរាប់ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## និងជាប្រធានគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការសំរាប់គោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញឯកសារចក្ខុវិស័យនិងផែនការសំរាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុពីឆ្នាំ២០០១-២០១០ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០១

-បានឃើញស្មារតីនៃកិច្ចចរចាររវាងតំណាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០១

-បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០១

# សម្រេច

**ប្រការ១:** បង្កើតក្រុមប្រតិបត្តិ (Task Force) ប្រចាំនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់កម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (Financial Sector Development Program, ADB Loan No 1859-CAM (SF)) ។ សមាសភាពនៃក្រុមប្រតិបត្តិនេះមានដូចតទៅ:

| | | |
|---|---|---|
| ១-លោក **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ | ប្រធាន |
| ២-លោក **រស់ ចរម** | អនុប្រធាននាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ | អនុប្រធាន |
| ៣-លោក **អ៊ុច សុមុនី** | មន្ត្រីការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី | សមាជិក |
| ៤-លោក **ស៊ុន សុខនី** | មន្ត្រីការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី | សមាជិក |
| ៥-លោកស្រី **ម៉ម ម៉ាណូលីន** | មន្ត្រីការិយាល័យធនាគារអភិវឌ្ឍន៍អាស៊ី | សមាជិក |

**ប្រការ ២:** ក្រុមប្រតិបត្តិនេះត្រូវបំពេញការងារក្រោមការណែនាំរបស់ប្រធានក្រុមប្រតិបត្តិដែលជាសមាជិកនៃក្រុមការងារបច្ចេកទេស និងជាអ្នកអនុវត្តការងារគំរោងប្រចាំថ្ងៃនូវភារកិច្ចដូចខាងក្រោម:

- រៀបចំឯកសារបង្វែរប្រាក់ពីធនាគារអភិវឌ្ឍន៍អាស៊ីមកគណនីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំឯកសារបង្វែរប្រាក់ពីគណនីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅធនាគារជាតិនៃកម្ពុជា មកគណនីរបស់ភ្នាក់ងារអនុវត្តគំរោងនៅធនាគារជាតិនៃកម្ពុជា
- ចាត់ចែង សំរបសំរួល និងត្រួតពិនិត្យ លើការប្រើប្រាស់ថវិកានៃគណនីកម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (Financial Sector Development Program, ADB Loan No 1859-CAM (SF)) របស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

**ប្រការ ៣:** អគ្គលេខាធិការ ខុទ្ទកាល័យ គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុព្រមទាំងសាមីខ្លួនដូចប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ សីហា ឆ្នាំ២០០២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

គាត ឈន់

**ចំឡងជូន:**

-ធនាគារជាតិនៃកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ...240......សសរ.កសក

# សេចក្តីសម្រេច

## ស្តីពីការតែងតាំងគណៈកម្មការប្រឹក្សាថ្នាក់ជាតិសំរាប់រៀបចំឯកសារ និង ស្រាវជ្រាវពូជសត្វនៅកម្ពុជា

***********

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ខែ វិច្ឆិកា ឆ្នាំ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០៦ /នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- តាមសំណើលិខិតលេខ ៣៤៦ ផប ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០០២ របស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ស្តីពីសំណើសុំបង្កើតគណៈកម្មការប្រឹក្សាថ្នាក់ជាតិដែលហៅកាត់ថា **NCC**

## <u>សំរេច</u>

**<u>ប្រការ១</u>:** តែងតាំងគណៈកម្មការប្រឹក្សាថ្នាក់ជាតិ សំរាប់រៀបចំឯកសារ និង ស្រាវជ្រាវពូជសត្វនៅកម្ពុជាដែលមានសមាសភាពដូចខាងក្រោម :

១- លោក **សួន សុធឿន** អនុប្រធាននាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ជាប្រធាន

២- លោក **លឹម ចាន់ធី** អនុប្រធានការិយាល័យផលិតកម្ម ជាអ្នកសំរបសំរួល

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១/ ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia Phone (023) 211 351/211 352, Fax . (855) 23 - 217 320

៣-លោក **ស៊ិន ចៅ** មន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ជាលេខាធិការ

៤-កញ្ញា **ហោ ម៉ាលីន** មន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ជាលេខាធិការ

៥-លោក **អ៊ឹុង សុគន** មន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ជាលេខាធិការ

៦-លោក **ស៊ាន កុសល** អនុប្រធានការិយាល័យផែនការគណនេយ្យ ជាសមាជិក

៧-លោក **ថន សុទីរ៉ា** មន្ត្រីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ជាសមាជិក

៨-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តកណ្តាល ជាសមាជិក

៩-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តក្រចេះ ជាសមាជិក

១០-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តបាត់ដំបង ជាសមាជិក

១១-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តស្ទឹងត្រែង ជាសមាជិក

១២-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តស្វាយរៀង ជាសមាជិក

១៣-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តពោធិសាត់ ជាសមាជិក

១៤-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តសៀមរាប ជាសមាជិក

១៥-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តកំពត ជាសមាជិក

១៦-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តកំពង់ស្ពឺ ជាសមាជិក

១៧-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តកំពង់ឆ្នាំង ជាសមាជិក

១៨-លោកប្រធានការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តកំពង់ធំ ជាសមាជិក

**ប្រការ២:** ក្រុមការងារនេះមានភារកិច្ចរៀបចំឯកសារ និង ស្រាវជ្រាវពូជសត្វនៅកម្ពុជា តាមឯកសារគោលនយោបាយផលិតកម្មសត្វ ដើម្បីផ្ញើជូនអង្គការ FAO ប្រចាំតំបន់នៅ ខែ សីហា ឆ្នាំ ២០០២ខាងមុខនេះ ។

**ប្រការ៣:** ប្រធានក្រុមការងារមានសិទ្ធិជ្រើសរើសសមាសភាពបន្ថែម ដើម្បីធ្វើជាជំនួយការ និង អញ្ជើញសមាជិកដើម្បីមកប្រជុំតាមការចាំបាច់ ។

**ប្រការ៤:** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ ប្រធាន នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល និង សាមីជនត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិ ភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២

ចន្ទ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

  "ដើម្បីជូនជ្រាប"
- ដូចប្រកា ៤ "ដើម្បីអនុវត្ត"
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MOSALVY

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ ២០៥ ស.ក.ប.យ.

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការផ្ទេរ ប្តូរឈ្មោះ និងបង្កើតការិយាល័យ
## ចំណុះនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជំនួយ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិ ទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកត/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- បានឃើញ អនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ៦៤០ សកអ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ របស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន
- បានឃើញប្រកាសលេខ ៣៩០ ស.ក.ប.យ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ៣៨៩ ស.ក.ប.យ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១:** ត្រូវបានប្តូរឈ្មោះ និងផ្ទេរការិយាល័យចំនួន ០៣ អោយស្ថិតនៅក្នុងការគ្រប់គ្រង របស់នាយកដ្ឋាន សហប្រតិបត្តិការ អន្តរជាតិ និងជំនួយ នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ដូចតទៅ :

១-ត្រូវបានប្តូរឈ្មោះ ការិយាល័យទំនាក់ទំនងអន្តរជាតិ មកជាការិយាល័យ អន្តរជាតិ និងជំនួយ

២-ផ្ទេរការិយាល័យអាស៊ានបច្ចុប្បន្ន ស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ របស់ប្រធានស្ថាប័ន មកស្ថិតក្រោមការគ្រប់គ្រង របស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជំនួយ នៃអគ្គនាយកដ្ឋានកិច្ចការ រដ្ឋបាល និងហិរញ្ញវត្ថុវិញ។

៣-ផ្ទេរការិយាល័យពិធីការ និងមន្ត្រីរាជការបច្ចុប្បន្ន ក្រោមការគ្រប់គ្រងរបស់ ខុទ្ទកាល័យ មកស្ថិតក្រោមការគ្រប់គ្រង របស់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជំនួយ នៃអគ្គនាយកដ្ឋាន កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុវិញ។

**ប្រការ២:** បង្កើតការិយាល័យ សហប្រតិបត្តិការ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ និងជំនួយ។

**ប្រការ៣:** នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋាន កិច្ចការ រដ្ឋបាល និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ និងជំនួយ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ និងស្ថាប័ន អង្គភាពពាក់ព័ន្ធ មានភារកិច្ច រៀង១ខ្លួនអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

អុិត សំហេង

<u>ចម្លងជូន</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់អង្គភាពចំនុះក្រសួង "ដើម្បីជូនជ្រាប"
- ដូចមានក្នុងប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០២

លេខ ២០៦ ស.ក.ប.យ.

# ប្រកាស
## ស្តីពី
## ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅ
## របស់ការិយាល័យចំណុះនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជំនួយ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកត/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនីតិសម្បទា
- បានឃើញ អនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ២០៥ ស.ក.ប.យ ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការបង្កើត ប្តូរឈ្មោះ និងផ្ទេរការិយាល័យចំណុះ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជំនួយ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ១:** ត្រូវបានកំណត់រៀបចំរចនាសម្ព័ន្ធ និងភារកិច្ចរបស់ការិយាល័យស្ថិតក្រោម នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងជំនួយ នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុដូចតទៅ :

១-ការិយាល័យសហប្រតិបត្តិការ

២-ការិយាល័យអន្តរជាតិ និងជំនួយ

៣-ការិយាល័យពិធីការ

៤-ការិយាល័យអាស៊ាន

**ប្រការ២:** ការិយាល័យនីមួយៗ មានភារកិច្ចដូចតទៅ :

**ក**-ការិយាល័យសហប្រតិបត្តិការ

-រៀបចំបែបបទទិដ្ឋាការចេញ-ចូលនិងបន្តទិដ្ឋាការស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជូនអង្គការជាតិ និងអន្តរជាតិ

-រៀបចំទទួល និងជូនដំណើគណៈប្រតិភូ.

-បកប្រែឯកសារ និងបកប្រែផ្ទាល់មាត់ជូនថ្នាក់ដឹកនាំក្រសួង.

-រៀបចំបែបបទសុំផ្លាកលេខ ក្នុងការប្រើប្រាស់ រថយន្ត ទោចក្រយានយន្ត ជូនអង្គការជាតិ និងអន្តរជាតិ (NGO-10).

-ទំនាក់ទំនងផ្តល់ពត៌មាន ជូនភ្ញៀវជាតិ និងអន្តរជាតិដូចជា :

១-ការស្នើសុំជួបពិភាក្សាជាមួយថ្នាក់ដឹកនាំក្រសួង

២-ការស្នើសុំមន្ត្រី ឬ ថ្នាក់ដឹកនាំក្រសួងទៅធ្វើទស្សនៈកិច្ចនៅបរទេស

-រៀបចំធ្វើលិខិតជូនពរភ្ញៀវជាតិ អន្តរជាតិ ក្នុងពិធីបុណ្យជាតិ និងអន្តរជាតិ

**ខ**- ការិយាល័យអន្តរជាតិ និងជំនួយ :

-ពិនិត្យ និងរៀបចំពិធីសារ រវាងក្រសួង ជាមួយអង្គការជាតិ និងអន្តរជាតិ.

-តាមដានគំរោងកម្មវិធី និងធ្វើការវាយតំលៃអំពីលទ្ធផលការងាររបស់អង្គការជាតិ និងអន្តរជាតិ.

-គ្រប់គ្រងឯកសាររបស់នាយកដ្ឋាន.

-បូកសរុបលទ្ធផលការងារ សប្តាហ៍ ខែ ត្រីមាស ឆមាស និងរបាយការណ៍ប្រចាំឆ្នាំរបស់នាយកដ្ឋាន.

-ធ្វើលិខិត សុំអនុញ្ញាតិនាំចូល ជំនួយមនុស្សធម៌តាមបណ្តាក្រសួងដែលពាក់ព័ន្ធ.

-សម្របសំរួល លិខិតគាំទ្រ គំរោងកម្មវិធី ជូនអង្គការជាតិ អន្តរជាតិ ដែលបានចុះសហប្រតិបត្តិការជាមួយក្រសួង។

**គ**-ការិយាល័យពិធីការ:

-សហការជាមួយនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ រៀបចំទទួលភ្ញៀវដែលត្រូវចូលរួមពិភាក្សាការងារ ជាមួយថ្នាក់ដឹកនាំក្រសួង រួមទាំងភ្ញៀវជាតិ និងអន្តរជាតិ.

-រៀបចំតុបតែងកន្លែងប្រារព្ធពិធីសំរាប់រដ្ឋមន្ត្រី ក្នុងពិធីកិត្តិយសផ្សេងៗ ដូចជាពិធីបុណ្យ ពិធីសម្ភោធ ពិធីប្រជុំ ដែលរៀបចំឡើងដោយក្រសួង.

-លើកគម្រោងថវិការ ជូននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ សំរាប់ចំណាយក្នុងពិធីនីមួយៗ។

**ឃ**-ការិយាល័យអាស៊ាន :

-ចូលរួមក្នុងគណៈកម្មាធិការ អាស៊ាន ផ្នែកអភិវឌ្ឍន៍សង្គមរបស់ក្រសួង.

-ធ្វើជាសេនាធិការអោយក្រសួង ក្នុងកិច្ចការសម្របសម្រួលរាល់កិច្ចការអាស៊ាន ជាមួយអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអគ្គលេខាធិការអាស៊ាន នៅហ្សាកាតា.

-ធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គភាពអាស៊ាន នៃក្រសួងនានា.

-ទំនាក់ទំនងជាមួយអង្គភាពនានា ដែលស្ថិតក្រោមឱវាទក្រសួង ស្រង់បាននូវពត៌មានសំខាន់ៗ និងសំណូមពរ ដែលពាក់ព័ន្ធដល់ការងារអាស៊ាន.

-ចូលរួមប្រជុំតាមកម្មវិធីកំណត់ប្រចាំឆ្នាំ នៃអង្គការអាស៊ានដែលមានការពាក់ព័ន្ធ ដល់វិស័យ សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា.

-ផ្សព្វផ្សាយ ពត៌មាន អំពីសកម្មភាពអាស៊ានជូនមន្ត្រីរាជការរបស់ក្រសួង.

-លើកគំរោងថវិការចំណាយប្រចាំឆ្នាំ នីមួយៗ សំរាប់ការងារអាស៊ានរបស់ខ្លួន.

-ធ្វើរបាយការណ៍អំពីសកម្មភាពការងារ ដែលមានការពាក់ព័ន្ធនឹងកិច្ចការអាស៊ាន ទៅតាមរបបកំណត់នៃអគ្គនាយកអាស៊ានជាតិ។

**ប្រការ៣:** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជា និរាករណ៍។

**ប្រការ៤:** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
  "ដើម្បីមុខងារ"
- ឯកសារ-កាលប្បវត្តិ

អ៊ិត សំហេង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ : ៦១១ អយក.ប្រក

# ប្រកាស
## ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ព្រៃកចំបាំ

## រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត ០៨៩៧-១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ .ប.ក ចុះថ្ងៃទី ២៣ - ៣ - ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា ព្រៃកចំបាំ ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០២ ដោយមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្តព្រៃវែង ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០២
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១** : - ប្តូរឈ្មោះសាលាបឋមសិក្សា **ព្រៃកចំបាំ** មកជាសាលាបឋមសិក្សា " **មីយ៉ាហ្សិតា យូស៊ីអូព្រៃកចំបាំ** " ដែលមានទីតាំងស្ថិតនៅ ឃុំ **មេសប្រចាន់** ស្រុក **ពារាំង** ខេត្ត **ព្រៃវែង** ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** : - បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣** : - នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ព្រៃវែង** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **ពារាំង** នាយកសាលាបឋមសិក្សា " **មីយ៉ាហ្សិតា យូស៊ីអូ ព្រៃកចំបាំ** " មានភារកិច្ចអនុវត្តប្រកាសនេះ ។

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត ព្រៃវែង

" ដើម្បីជូនជ្រាបជាពត៌មាន "

- ដូចប្រការ ៣
- កាលប្បវត្តិ
- ឯកសារ នា -ប.ម

ភ្នំពេញ ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០២
ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៦១៥ អយក-ប្រក

*************

# ប្រកាស

## ស្តីពីការបើកសាលាបឋមសិក្សា ឃ្លាំងមឿង

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦- ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានពិនិត្យលិខិតស្នើសុំរបស់គណៈកម្មការសាងសង់សាលាបឋមសិក្សា ឃ្លាំងមឿង ចុះថ្ងៃទី ០៥ មិថុនា ឆ្នាំ ២០០២ ដោយមានចំណារឯកភាព របស់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត តាកែវ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០២ ។

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សម្រេច**

**ប្រការ១** :- បើកសាលាបឋមសិក្សា **ឃ្លាំងមឿង** ដែលមានទីតាំងស្ថិតនៅ ឃុំ **ផ្សែស** ស្រុក **បាទី** ខេត្ត **តាកែវ** ជាសាលាបឋមសិក្សា ពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :- សាលាបឋមសិក្សា **ឃ្លាំងមឿង** ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** :- នាយក នាយករង មានសិទ្ធទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** :- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **តាកែវ** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **បាទី** នាយកសាលាបឋមសិក្សា **ឃ្លាំងមឿង** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

អ៊ឹម_សេធី

**<u>កន្លែងទទួល</u>** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" <u>ដើម្បីជូនជ្រាបជាពត៌មាន</u> "

- សាលាខេត្ត តាកែវ

" <u>ជូនជ្រាបជាពត៌មាន</u> "

- ដូចប្រការ ៥
- កាលប្បវត្តិ - ឯកសារ នា.បម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៧៣ ❖ ៤៤

ក្រសួងអប់រំ យុវជន និង កីឡា
លេខ ៦១៦ អយក.ប្រក

## ប្រកាស
### ស្ដីពីការផ្ដាច់សាលាឧបសម្ព័ន្ធ គោករមៀត មកជាសាលាបឋមសិក្សាពេញលក្ខណៈ

### រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ ៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានពិនិត្យលិខិតលេខ ០១១ បឋ.កណ ចុះថ្ងៃទី ២០ ខែ ៤ ឆ្នាំ ២០០១ របស់នាយកសាលាបឋមសិក្សា ឃុំ កណ្ដោក ដែលមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កណ្ដាល

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

### សម្រេច

**ប្រការ១:**- ផ្ដាច់សាលាឧបសម្ព័ន្ធ **គោករមៀត** ពីសាលាបឋមសិក្សា **កណ្ដោក** ដែលមានទីតាំងស្ថិត ឃុំ **កណ្ដោក** ស្រុក **កណ្ដាលស្ទឹង** **ខេត្តកណ្ដាល** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២:**- សាលាបឋមសិក្សា **គោករមៀត** ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:**- នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:**- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:**- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡាខេត្ត **កណ្ដាល** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **កណ្ដាលស្ទឹង** នាយកសាលាបឋមសិក្សា **គោករមៀត** នាយកសាលាបឋមសិក្សា **កណ្ដោក** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២
ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា
រដ្ឋលេខាធិការ
ទ្រឹម_សិទ្ធិ

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាខេត្តកណ្ដាល

" ដើម្បីជូនជ្រាបជាពតិមាន "

- ដូចប្រការ ៥
- កាលប្បវត្តិ- ឯកសារ នា -ប.ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា
លេខ : ៦១៧ អយក-ប្រក

# ប្រកាស
## ស្តីពីការបើកសាលាបឋមសិក្សា ក្បាលកោះ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦- ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានពិនិត្យលិខិតស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡាខេត្ត កំពង់ឆ្នាំង លេខ ១៦២៩ អយក.កឆ ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០២ ។

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ១** :- បើកសាលាបឋមសិក្សា **ក្បាលកោះ** ជាផ្លូវការដែលមានទីតាំងស្ថិតនៅភូមិ **ក្បាលកោះ** ឃុំ **នំបិលទឹក** ស្រុក **កំពង់ត្រឡាច** ខេត្ត **កំពង់ឆ្នាំង** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **កំពង់ក្តារ** ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :- សាលាបឋមសិក្សា **ក្បាលកោះ** ត្រូវមានប្រធានក្រុមម្នាក់ទទួលខុសត្រូវរួមជាមួយនាយក សាលាបឋមសិក្សា **កំពង់ក្តារ** ។

**ប្រការ៣** :- បទបញ្ញតិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពង់ឆ្នាំង** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **កំពង់ត្រឡាច** នាយកសាលាបឋមសិក្សា **កំពង់ក្តារ** និងប្រធានក្រុមសាលាឧបសម្ព័ន្ធ **ក្បាលកោះ** មានភារកិច្ច អនុវត្តប្រកាសនេះ ។

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាបជាពតិមាន "
- សាលាខេត្ត កំពង់ឆ្នាំង

" ជូនជ្រាបជាពតិមាន "
- ដូចប្រការ ៤
- កាលប្បវត្តិ
- ឯកសារ នា -ប.ម

ភ្នំពេញ ,ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២
ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ

ទុំ ម_និទ្ធិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំយុវជន និង កីឡា**
**លេខ : ៦១៤ អយក.ប្រក**

## ប្រកាស
### ស្តីពីការបើកសាលាបឋមសិក្សា ត្រាំងចំបក់

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
-បានពិនិត្យលិខិតលេខ ១៦៧ អយក.សពវ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០០១ របស់ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក ព្រៃវែង ដោយមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ព្រៃវែង ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ។
-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១** :-បើកសាលាបឋមសិក្សា **ត្រាំងចំបក់** ដែលមានទីតាំងស្ថិតនៅ ភូមិ **ត្រាំងចំបក់** ឃុំ **ពានសាង** ស្រុក **ព្រៃវែង** ខេត្ត **ព្រៃវែង** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **ព្រៃជ្រាំង** ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :-សាលាបឋមសិក្សា **ត្រាំងចំបក់** ត្រូវមានប្រធានក្រុមម្នាក់ទទួលខុសត្រូវរួមជាមួយនាយកសាលាបឋមសិក្សា **ព្រៃជ្រាំង** ។

**ប្រការ៣** :-បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤** :-នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ព្រៃវែង ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **ព្រៃវែង** នាយកសាលាបឋមសិក្សា **ត្រាំងចំបក់** និង ប្រធានក្រុមសាលាឧបសម្ព័ន្ធ **ព្រៃជ្រាំង** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២
**ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា**
**រដ្ឋលេខាធិការ**

**ទុំ..សិទ្ធ**

**<u>កន្លែងទទួល</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
" ដើម្បីជូនជ្រាបជាពត៌មាន "
- សាលាខេត្ត ព្រៃវែង " ជូនជ្រាបជាពត៌មាន "
- ដូចប្រការ ៤- កាលប្បវត្តិ - ឯកសារ ទា -ប.ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣ ❖ ៤៥

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៦១៥ អយក-ប្រក

## ប្រកាស

## ស្ដីពីការបើកសាលាបឋមសិក្សា ចតុមណ្ឌល

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦- ០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានពិនិត្យលិខិតលេខ ៣៤៦ អយក.ពវ.បម ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០២ របស់មន្ទីរអប់រំ យុវជន និង កីឡាខេត្ត ព្រៃវែង។

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១** :- បើកសាលាបឋមសិក្សា **ចតុមណ្ឌល** ជាផ្លូវការដែលមានទីតាំងស្ថិតនៅភូមិ **ក្រវ៉ាន់** ឃុំ **ក្រញ្ចូង** ស្រុក **កំចាយមារ** ខេត្ត **ព្រៃវែង** ជាសាលាបឋមសិក្សាពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :- សាលាបឋមសិក្សា **ចតុមណ្ឌល** ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា។

**ប្រការ៣** :- នាយក នាយករង មានសិទ្ធទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការក៏នត់របស់រដ្ឋ។

**ប្រការ៤** :- បទបញ្ញាតិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **ព្រៃវែង** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **កំចាយមារ** នាយកសាលាបឋមសិក្សា **ចតុមណ្ឌល** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សេធី**

**<u>កន្លែងទទួល</u>** :

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

" <u>ដើម្បីជូនជ្រាបជាពតិមាន</u> "

- សាលាខេត្ត ព្រៃវែង

" <u>ជូនជ្រាបជាពតិមាន</u> "

- ដូចប្រការ ៥
- កាលប្បវត្តិ - ឯកសារ នា.បម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៥ ❖ ៤៨

**ក្រសួងអប់រំ យុវជន និង កីឡា**

**លេខ ៦២០ អយក.ប្រក**

## ប្រកាស

ស្តីពីការផ្លាច់សាលាឧបសម្ព័ន្ធ **ឧទុលសាលា**

មកជាសាលាបឋមសិក្សាពេញលក្ខណៈ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានពិនិត្យលិខិតលេខ ១០១ សព.អប ចុះថ្ងៃទី ៣០ ខែ ៣ ឆ្នាំ ២០០១ របស់នាយកសាលាបឋមសិក្សា សម្តេចក្រុមព្រះ នរោត្តមរណឫទ្ធិ ឃុំ អន្លង់រមៀត ដែលមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កណ្តាល

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១:**- ផ្តាច់សាលាឧបសម្ព័ន្ធ **ឧទុលសាលា** ពីសាលាបឋមសិក្សា **សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ** ដែលមានទីតាំងស្ថិតនៅ ឃុំ **អន្លង់រមៀត** ស្រុក **កណ្តាលស្ទឹង ខេត្តកណ្តាល** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២:**- សាលាបឋមសិក្សា **ឧទុលសាលា** ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣:**- នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤:**- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥:**- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡាខេត្ត **កណ្តាល** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក **កណ្តាលស្ទឹង** នាយកសាលាបឋមសិក្សា **សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា**

**រដ្ឋលេខាធិការ**

**ទុំ_សិទ្ធិ**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាខេត្តកណ្តាល

"ដើម្បីជូនជ្រាបជាពត៌មាន"

- ដូចប្រការ ៥
- កាលប្បវត្តិ- ឯកសារ នា -ប.ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

**លេខ ៦៧១ អយក.ប្រក**

# ប្រកាស

## ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ **សំបូរមាស** មកជាសាលាបឋមសិក្សាពេញលក្ខណៈ

---

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

-បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា

-បានពិនិត្យលិខិតលេខ ១២ អយក.ខដ ចុះថ្ងៃទី ១៣ ខែ ២ ឆ្នាំ ២០០២ របស់ការិយាល័យអប់រំ យុវជន និង កីឡា ខណ្ឌ **ដង្កោ** រាជធានីភ្នំពេញ

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សម្រេច

**ប្រការ១** :- ផ្តាច់សាលាឧបសម្ព័ន្ធ **សំបូរមាស** ពីសាលាបឋមសិក្សា **ដង្កោ** ដែលមានទីតាំងស្ថិតនៅភូមិ **សំបូរ** សង្កាត់ **ដង្កោ** ខណ្ឌ **ដង្កោ** **រាជធានី ភ្នំពេញ** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** :- សាលាបឋមសិក្សា **សំបូរមាស** ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** :- នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** :- បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** :- នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា **រាជធានីភ្នំពេញ** ការិយាល័យអប់រំ យុវជន និង កីឡា ខណ្ឌ **ដង្កោ** នាយកសាលាបឋមសិក្សា **សំបូរមាស** នាយកសាលាបឋមសិក្សា **ដង្កោ** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០២

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា**

រដ្ឋលេខាធិការ

**ទ្រឹង_សិទ្ធិ**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាក្រុងភ្នំពេញ

"ដើម្បីជូនជ្រាបជាពត៌មាន"

- ដូចប្រការ ៥
- កាលប្បវត្តិ
- ឯកសារ នា -ប.ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**

លេខ...១៥៣/០២...ព.ម ក.ប.គ

រាជធានីភ្នំពេញ,ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០២

# ប្រកាស

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

******

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ នស.រ.ក.ត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស.រ.ក.ម ០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពត៌មាន ។
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសឱ្យប្រើច្បាប់ស្ដីពីរបបសារពត៌មាន ។
- បានឃើញអនុក្រឹត្យលេខ ៧០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន ។
- បានឃើញលិខិតរបស់លោក សំ ផាន់ណារិទ្ធ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០២ ស្ដីពីសំណើសុំច្បាប់បោះពុម្ពផ្សាយកាសែត "ព្រំដែនខ្មែរ" ។

## សម្រេច

**ប្រការ១ :** អនុញ្ញាតឱ្យបោះពុម្ពផ្សាយកាសែត "**ព្រំដែនខ្មែរ**" ដែលមានលោក **សំ ផាន់ណារិទ្ធ** ជាម្ចាស់ហាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ២៩ ផ្លូវលេខ១៣៥ ក្រុមទី១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ។

**ប្រការ២ :** រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្ដីពីរបបសារពត៌មាន ក្រមសីលធម៌អ្នកសារពត៌មាន ។

**ប្រការ៣ :** ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការ ២ ខាងលើ សាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៤ :** អគ្គនាយករដ្ឋបាល និងសោតទស្សន៍ ប្រធាននាយកដ្ឋានមជ្ឈមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងម្ចាស់ហាងការផ្សាយកាសែត "**ព្រំដែនខ្មែរ**" ត្រូវអនុវត្តនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៥ :** ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល២ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាយុកាលនៃអាជ្ញាប័ណ្ណលើសរយៈពេល៣ខែ ក្រសួងពត៌មានចាត់ទុកថា សាម៉ីម្ចាស់ហាងបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**

លឺ ឡាយស្រេង

**ចម្លងជូន**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យមេធាវីរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- អភិបាលរាជធានីភ្នំពេញ
- តុលាការរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារពត៌មានកម្ពុជា "ដើម្បីជ្រាបជាពត៌មាន"
- សាម៉ីខ្លួន

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពត៌មាន**

លេខ.......................ព.ម

រាជធានីភ្នំពេញ,ថ្ងៃទី..........ខែ..........ឆ្នាំ..........

# ប្រកាស
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

******

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រ.ក.ត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន ។
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ច្បាប់ស្តីពីរបបសារពត៌មាន ។
- បានឃើញអនុក្រឹត្យលេខ ៧០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន ។
- បានឃើញប្រកាសរបស់ក្រសួងពត៌មានលេខ ០៨១/៩៨ ពម.ប្រក ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ១៩៩៨ អនុញ្ញាតឱ្យបោះពុម្ពផ្សាយកាសែត "ជាតិកម្ពុជា" ដែលមានលោក ហ៊ុន ផានិត ជាចាងហ្វាងការផ្សាយ ។
- បានឃើញលិខិតផ្ទេរសិទ្ធរបស់លោក ហ៊ុន ផានិត ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីសំណើសុំប្តូរចាងហ្វាងការផ្សាយមកលោក ជឹង គីមម៉េង ជាចាងហ្វាងការផ្សាយជំនួសវិញ ។

## សម្រេច

**ប្រការ១** : អនុញ្ញាតឱ្យផ្ទេរសិទ្ធិចាងហ្វាងការផ្សាយកាសែត"**ជាតិកម្ពុជា**" ពីលោក **ហ៊ុន ផានិត** ទៅលោក **ជឹង គីមម៉េង** ជាចាងហ្វាងការផ្សាយវិញ ។ ទីស្នាក់ការផ្ទះលេខ៣៨ ផ្លូវលេខ៧០ ភូមិ២៤ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

**ប្រការ២** : ប្រកាសរបស់ក្រសួងពត៌មានលេខ ០៨១/៩៨ ពម.ប្រក ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣** : រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារពត៌មាន ក្រមសីលធម៌អ្នកសារពត៌មាន ។

**ប្រការ៤** : ករណីប្រព្រឹត្តល្មើសនឹងប្រការពខាងលើ សាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ ជាធរមាន ។

**ប្រការ៥** : អគ្គនាយករដ្ឋបាល និងសោតទស្សន៍ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន និងចាងហ្វាងការផ្សាយកាសែត"**ជាតិកម្ពុជា**" ត្រូវអនុវត្តនូវប្រកាសនេះ ។

**ប្រការ៦** : ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាយុកាល នៃអាជ្ញាប័ណ្ណលើសរយៈពេល ៣ខែ ក្រសួងពត៌មានចាត់ទុកថា សារពត៌មាននេះបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យមេដឹកនាំរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- តុលាការរាជធានីភ្នំពេញ
- អភិបាលរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- សម្ព័ន្ធអ្នកសារពត៌មានកម្ពុជា
- "ដើម្បីជ្រាបជាពត៌មាន"
- សាម៉ីខ្លួន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពត៌មាន

លេខ ១៥៤/...ព.ម ...

រាជធានីភ្នំពេញ,ថ្ងៃទី ... ខែ ... ឆ្នាំ ...

# ប្រកាស

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

******

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រ.ក.ត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន ។
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារពត៌មាន ។
- បានឃើញអនុក្រឹត្យលេខ៧០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពត៌មាន ។
- បានឃើញប្រកាសបិទរបស់ក្រសួងពត៌មានលេខ ១២៦/០២ ពម.ប្រក ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០០២ ។
- បានឃើញលិខិតរបស់លោក **ម៉ី សន្តិភាព** ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០២ ស្តីពីសំណើសុំអនុញ្ញាតធ្វើការបោះពុម្ពផ្សាយកាសែត " **កម្ពុជាវរសេរី** " ជាថ្មីឡើងវិញ ។

## សំរេច

**ប្រការ១:** អនុញ្ញាតឱ្យកាសែត "**កម្ពុជាវរសេរី**" បោះពុម្ពចែកផ្សាយឡើងវិញដោយមានលោក **ម៉ី សន្តិភាព** ជាចាងហ្វាងការផ្សាយ ។ អាស័យដ្ឋានទីស្នាក់ការផ្ទះលេខ៦$E_3$ ផ្លូវលេខ១៦៨ ណ្ហើ៧មករា ក្រុងភ្នំពេញ ។

**ប្រការ២:** រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារពត៌មាន ក្រមសីលធម៌អ្នកសារពត៌មាន ។

**ប្រការ៣ :** ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការ២ ខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៤ :** អគ្គនាយករដ្ឋបាល និងសោតទស្សន៍ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន និងចាងហ្វាងការផ្សាយកាសែត "**កម្ពុជាវរសេរី**" ត្រូវអនុវត្តនូវប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៥ :** ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាយុកាល នៃអាជ្ញាប័ណ្ណលើសរយៈពេល៣ខែ ក្រសួងពត៌មានចាត់ទុកថា សាមីចាងហ្វាងបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**

លី. ធុយអេង

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យមេធាវីរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- អភិបាលរាជធានីភ្នំពេញ
- តុលាការរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- គ្រប់សមាគមអ្នកសារពត៌មានកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

**ក្រសួងព័ត៌មាន**

លេខ ១៥៥ ព.ម

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០២

# ប្រកាស

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព័ត៌មាន

******

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។
- បានឃើញព្រះរាជក្រឹត្យ ន.ស.រ.ក.ត/១១៩៨/៧២ ចុះថ្ងៃ ទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃ ទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស.រ.ក.ម ០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន ។
- បានឃើញព្រះរាជក្រមលេខ នស/រកម ០៨៩៥-០៧ ចុះថ្ងៃ ទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ច្បាប់ស្តីពីរបបសារព័ត៌មាន ។
- បានឃើញអនុក្រឹត្យលេខ ៧០ អ.ន.ក្រ.បក ចុះថ្ងៃ ទី៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងព័ត៌មាន ។
- បានឃើញប្រកាសរបស់ក្រសួងព័ត៌មាន លេខ ២៧២/០០ ពម.ប្រកចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការអនុញ្ញាតឱ្យទស្សនាវដ្តី " **ខ្មែរអាទិត្យ** " ដំណើរការបោះពុម្ពចែកផ្សាយដោយមានលោក **ឈាង ស៊ីម** ជាចាងហ្វាងការផ្សាយ ។
- បានឃើញលិខិតរបស់លោក **ឈាង ស៊ីម** ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០២ សំណើសុំប្តូរពីទស្សនាវដ្តី" **ខ្មែរអាទិត្យ** "មកជាកាសែតឈ្មោះ " **គីឡា** " ។

## សម្រេច

**ប្រការ១ :** អនុញ្ញាតឱ្យទស្សនាវដ្តី " **ខ្មែរអាទិត្យ** "ប្តូរមកជាកាសែត" **គីឡា** "វិញ និងដំណើរការបោះពុម្ពចែកផ្សាយ ដោយមានលោក **ឈាង ស៊ីម** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ២៦អា ផ្លូវលេខ៣៣៦ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។

**ប្រការ២ :** ប្រកាសរបស់ក្រសួងព័ត៌មានលេខ ២៧២/០០ ពម.ប្រក ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០០០ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣ :** រាល់ដំណើរការបោះពុម្ពចែកផ្សាយ ត្រូវគោរពតាមច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីរបបសារព័ត៌មាន ក្រមសីលធម៌អ្នកសារព័ត៌មាន ។

**ប្រការ៤ :** ក្នុងករណីប្រព្រឹត្តល្មើសនឹងប្រការពខាងលើ សាមីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥ :** អគ្គនាយករដ្ឋបាល និង សោតទស្សន៍ ប្រធាននាយកដ្ឋានមណ្ឌលព័ត៌មាននៃក្រសួងព័ត៌មាន និង ចាងហ្វាងសារព័ត៌មាន " **គីឡា** " ត្រូវអនុវត្តនូវប្រកាសនេះ ។

**ប្រការ៦ :** ប្រកាសនេះមានប្រសិទ្ធភាពរយៈពេល ២ឆ្នាំ ។ ក្នុងករណីមិនសុំបន្តអាយុកាលនៃអាជ្ញាប័ណ្ណលើសរយៈពេល៣ខែ ក្រសួងព័ត៌មានចាត់ទុកថា សារព័ត៌មាននេះបានបោះបង់អាជីវកម្មរបស់ខ្លួនជាស្ថាពរ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

ម៉ី. ខៀវកញ្ញារិទ្ធ

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យនៃរាជរដ្ឋាភិបាល
- ក្រសួងយុត្តិធម៌
- តុលាការរាជធានីភ្នំពេញ
- ក្រសួងមហាផ្ទៃ
- អភិបាលរាជធានីភ្នំពេញ
- ស្នងការនគរបាលរាជធានីភ្នំពេញ
- គ្រប់សមាគមន៍សារព័ត៌មាន
- " ដើម្បីជ្រាបជាព័ត៌មាន "
- សាមីខ្លួន